# ការបង្កាត់ពូជ

ការបង្កាត់ពូជមាន ២របៀបគឺ ការបង្កាត់ដោយប្រើបា និងការបង្កាត់ដោយប្រើលិង្គ សិប្បនិម្មិត ។

## ការបង្កាត់ដោយប្រើបា

**ត្រូវជ្រើសរើសបាណាដែលមានសុខភាពល្អ និងគ្មានជំងឺឆ្លង ។**

ត្រូវសំអាតប្រដាប់បន្តពូជមេ និងបាជាមុនសិន ។ ពេលបាមកដល់ ត្រូវឲ្យវាសំរាក ១៥នាទី ដើម្បីឲ្យវាបាត់ហត់ ទើបឲ្យវាឡើងពាក់មេរយៈពេល ពី ១០ ទៅ ១៥នាទី នៅកន្លែងដែល រាបស្មើ និងស្ងាត់ល្អ ។

### តើសញ្ញាអ្វីខ្លះដែលបញ្ជាក់ថា មេជ្រូករកឈ្មោល ?



មេជ្រូកមិនសូវស៊ីចំណី ខ្លួនរបស់វាឡើងកំដៅចូលចិត្តកកេរទ្រុង ប្រដាប់បន្តពូជឡើងពណ៌ក្រហម ហើយរីកធំជាងធម្មតា ពេលខ្លះវាឡើងពាក់ជ្រូកដទៃ ហើយពេលយើងយកដៃសង្កត់លើខ្នងវា វានៅស្ងៀម ត្រចៀកបះឡើងត្រង់ រង់ចាំ ការឡើងពាក់ ។

### ជៀសវាង

ចំពោះមេក្រមុំ មិនត្រូវដាក់ឈ្មោល ពេលវារកឈ្មោលលើកទី១ទេ ។ ត្រូវរង់ចាំ ការរកឈ្មោលលើកទី២ ព្រោះជាពេលដែលអាចបង្កកំណើតបានល្អ ។ ចន្លោះពេលរកឈ្មោលពី ១លើក ទៅ ១លើក មាន ២១ថ្ងៃ ។

### ការបង្កាត់សិប្បនិម្មិត



**បង្កាត់តាមសិប្បនិម្មិត គឺជៀសផុតពីការឆ្លង មេរោគផ្សេងៗ និងទទួលបានការបង្កកំណើត ខ្ពស់ តែមានតម្លៃថ្លៃ ។**

គេយកទឹកកាមរបស់ជ្រូកបាបាញ់បញ្ចូលទៅក្នុងប្រដាប់បន្តពូជជ្រូកមេ តាមរយៈលិង្គសិប្បនិម្មិត ។ មិនត្រូវបង្កាត់តាមសិប្បនិម្មិតដោយខ្លួនឯងទេ ត្រូវហៅភ្នាក់ងារសុខភាពសត្វ (បសុពេទ្យ) តាមភូមិ ឬស្រុក មកបង្កាត់ ។

## គួរដឹង

- មេជ្រូករកឈ្មោលពី២ទៅ៣ថ្ងៃ តែគួរដាក់ឈ្មោលនៅល្ងាចថ្ងៃទី១១ និងដាក់ម្តងទៀតនៅព្រឹកថ្ងៃទី២ ។
- ការដាក់ឈ្មោលទទួលបានជោគជ័យលុះត្រាតែ២១ថ្ងៃក្រោយពីការដាក់ឈ្មោលជាថ្មីទេ ហើយវាស៊ីផឹក និងដេកច្រើន ។

## តើមេជ្រូកផើមប៉ុន្មានថ្ងៃទើបកើតកូន ?

រយៈពេលមធ្យមមាន ១១៤ថ្ងៃ ឬ៣ខែ ៣អាទិត្យ និង៣ថ្ងៃ ។ ឧទាហរណ៍ បើយើងដាក់ឈ្មោល នៅថ្ងៃទី១ ខែមករា នោះមេជ្រូកនឹងកើតកូននៅថ្ងៃទី២៤ ខែមេសា ។

ចំពោះមេជ្រូកដែលមានកូនដំបូង ការពរពោះអាចយូរជាង គឺលើស២ ឬ៣ថ្ងៃ ។

(ដកស្រង់ចេញពីទស្សនាវដ្តី របស់អង្គការពេទ្យសត្វគ្មានព្រំដែន)